# ការចិញ្ចឹមមាន់

# គោលបំណងនៃការចិញ្ចឹមមាន់

- ផ្តល់សាច់ និង ស៊ុត
- ផ្តល់លាមកសំរាប់ធ្វើជី
- បង្កើនប្រាក់ចំណូលសំរាប់គ្រួសារ
- បង្កើនមុខរបរ

# ការគ្រប់គ្រងលើការចិញ្ចឹមមាន់

I- ការធ្វើទ្រុង

១-សារៈប្រយោជន៍នៃការធ្វើទ្រុង

- ងាយស្រួលក្នុងការផ្តល់ចំនី និង ទឹក
- ងាយស្រួលក្នុងការតាមដាន  និងចាក់ថ្នាំការពារ
- ងាយស្រួលក្នុងការធ្វើអនាម័យ

## ២-ការសាងសង់ទ្រុង

- សង់លើដីទួល មិនលិចទឹក ឬជាំទឹក
- ទ្រុងមានជញ្ជាំង មានទ្វារ
- ជុំវិញទ្រុង មានដាំដើមឈើ
- មានពន្លឺថ្ងៃចូល គ្រប់គ្រាន់
- ផ្ទៃក្រឡា ១ ម$^{២}$ សំរាប់ មាន់ ៣-៤ ក្បាល

- សង់បណ្ដោយថ្ងៃ

- ទ្រុងត្រូវមានកំពស់ ២,៥-៣ ម

- បណ្ដោយ ៤ ម X ទទឹង ៣ ម

- ត្រូវមានទ្រនំ សំរាប់មាន់ដេក និងពង

- ត្រូវមានស្នូកទឹក ចំណី

# II- ការផ្ដល់ទឹក

សារៈប្រយោជន៍នៃការផ្ដល់ទឹក

- ដើម្បីការលូតលាស់ និងផលិតពង
- មាន់អាចស្លាប់ប្រសិនបើគ្មានទឹកផឹក ២៤ ម
- កូនមាន់ ១០ ក្បាលត្រូវការទឹក ២,៥ លីត្រ /ថ្ងៃ
- មាន់ធំ ៤ ក្បាលត្រូវការទឹក ១ លីត្រ /ថ្ងៃ

# III- ការផ្តល់ចំណី

ដើម្បីអោយមាន់លូតលាស់ធំធាត់ល្អ ពងបានច្រើនៈ

- ចំណីត្រូវមានជាតិសាច់ សំរាប់ការលូតលាស់

- វីតាមីនមាននៅក្នុងរុក្ខជាតិបៃតង

- សារៈធាតុរ៉ែសំរាប់ការលូតលាស់ឆ្អឹង និងសំបកស៊ុត

# ការផ្សំចំណីសំរាប់មាន់ ១០ ក្បាល

- កន្ទក់ ១៥ គក្រ
- ម្សៅពោតក្រហម ១០ គក្រ
- ម្សៅត្រី ៥ គក្រ
- ម្សៅប្រេមិច 0.៤ គក្រ
- ស្លឹកកន្ធំធេត 0.២ គក្រ
- កញ្ចុងអង្ករ ១៤ គក្រ
- អំបិល 0.២ គក្រ

# IV- អំពីពូជ

១-ពូជមាន់បរទេស

- វៃឡឺហ្គន សំរាប់យកស៊ុត ២00-២៨0 /ឆ្នាំ
- មាន់ភ្លីមុត ចិញ្ចឹមយកសាច់ ២.៥-៣.៥ គក្រ

ស៊ុត ១៧0-១៩0 /ឆ្នាំ

## ២-ពូជក្នុងស្រុក

មានមាន់ ក្រញ៉ាស់ ស្គួយ ខ្មៅ សំពៅ ប្រជល់ និង សំឡី

- រកចំណី ក្រាបពង ដោយខ្លួនឯង
- សាច់មានរសជាតិឆ្ងាញ់
- ធន់ទ្រាំនឹង ជំងឺ អាកាសធាតុ

៣-ការជ្រើសរើសពូជ

- មាន់មានសុខភាពល្អ
- អាយុចាប់ពី ១ ថ្ងៃ យើងពិនិត្យមើលជើងជំពុះ ភ្នែក
- អាយុ ពី ២-៤ អាទិត្យ ពិនិត្យមើលការស៊ីចំណី ជើងរឹងមាំ រោមរលោង ក្តោបស្លាប
- មេមាន់មានទំងន់ ១.៥ គក្រ ឡើងទៅ
- មាន់បាមានទំងន់២ គក្រ ឡើងទៅ

# V- អនាម័យ និង វិធានការការពារ

## ១-អនាម័យ ៖

- សំអាតស្នូកទឹក ចំណី ជាប្រចាំ
- ទ្រុងត្រូវស្អាត ស្ងួត (លាមកកើបចេញទៀងទាត់)
- មាន់ដែលឈឺងាប់ត្រូវដុត ឬកប់ចោល (អនាម័យទ្រុង)

២-វិធានការការពារ

- ចាក់ថ្នាំការពារជំងឺអោយបានទៀងទាត់

- វ៉ាក់សាំង ១មុខ ការពារជំងឺបានតែ ១ មុខ

* ជំងឺ ញូកាសប្រើវ៉ាក់សាំង អាយធូ (បន្តក់)

* ជំងឺ អុតប្រើវ៉ាក់សាំងអុត (ជួសស្លាប)

* ជំងឺ អាសន្នរោគប្រើវ៉ាក់សាំង អាសន្នរោគ

# សូមអរគុណ